# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ជូនចំពោះលោកប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**លោកប្រធានជាទីគោរព**

នៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១៩ ខ្ញុំបានចុះបញ្ជីបណ្ដឹងសាទុក្ខជំទាស់នឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២។

ខ្ញុំតែងតែនិយាយថា គោលបំណងសំខាន់បំផុតរបស់ខ្ញុំ គឺការប្រាប់ប្រជាជនកម្ពុជា និងពិភពលោកអំពីការពិត។

សម្រាប់ហេតុផលនេះហើយ ដែលបណ្ដឹងសាទុក្ខរបស់ខ្ញុំនឹងជាឱកាសចុងក្រោយដើម្បីជម្រាបអំពីការពិត។

នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានចំណាយពេលជិតពីរឆ្នាំដើម្បីចេញសាលដីកា។ សំណុំរឿង ០០២/០២ មានទំហំធំជាងឆ្ងាយណាស់ ហើយវាជាសំណុំរឿងមានភាពស្មុគស្មាញជាងសំណុំរឿង ០០២/០១ ហើយខ្ញុំមានការព្រួយបារម្ភថា អង្គជំនុំជម្រះអាចប្រើរយៈពេលយូរជាងនេះ ដើម្បីចេញសាលដីកាសម្រាប់សំណុំរឿង ០០២/០២។

ខ្ញុំបានពិភាក្សាជាមួយសហមេធាវីការពារក្ដីរបស់ខ្ញុំ ហើយខ្ញុំបានជម្រាបគាត់ថា ខ្ញុំចង់បន្តតស៊ូដោយមិនគិតពីពេលវេលា បើទោះជាវាអាចយូរក៏ដោយ។

អាស្រ័យហេតុនេះហើយ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំផ្ដល់សិទ្ធិជាលាយលក្ខណ៍អក្សរនេះដោយអនុញ្ញាតឲ្យសហមេធាវីការពារក្ដីរបស់ខ្ញុំលោក សុន អរុណ, លោក លីវ សុវណ្ណា និង លោកស្រី Doreen Chen

និងសមាជិកគ្រួសាររបស់ខ្ញុំដែលមានក្នុងបញ្ជីភ្ជាប់ជាមួយនេះ ដើម្បីបន្តដំណើរការនីតិវិធី ធ្វើការដាក់ឯកសារ ឬក៏ផ្តួចផ្តើមនីតិវិធីនៅ អវតក ក្នុងនាមរូបខ្ញុំបាទ នៅក្នុងករណីដែលខ្ញុំស្លាប់នៅមុនពេល ឬបន្ទាប់ពីការចេញសាលដីកា។

សូមលោកប្រធានជ្រាប និងទទួលនូវការគោរពពីខ្ញុំបាទ។

នួន ជា

ធ្វើនៅភ្នំពេញ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៩

01623937

F46/2.1.1

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

# ឧបសម្ព័ន្ធនៃលិខិតចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

ខ្ញុំបាទ សូមគោរពជម្រាបជូន លោកប្រធានអង្គជំនុំជម្រះតុលាការកំពូល មេត្តាជ្រាបថា ដោយយោងតាមស្មារតីនៃលិខិតចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់ខ្ញុំបាទ ខ្ញុំសូមប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនសហមេធាវីការពារក្ដីរបស់ខ្ញុំ លោក សុន អរុណ, លោក លីវ សុវណ្ណា និង លោកស្រី Doreen Chen និង សមាជិកគ្រួសាររបស់ខ្ញុំ ដើម្បីបន្តដំណើរការនីតិវិធីធ្វើការដាក់ឯកសារ ឬក៏ផ្ដួចផ្ដើមនីតិវិធីទៅ អ.វ.ត.ក ក្នុងនាមរូបខ្ញុំបាទ នៅក្នុងករណីដែលខ្ញុំស្លាប់នៅមុនពេល ឬបន្ទាប់ពីការចេញសាលដីកា។ បញ្ជីឈ្មោះ សមាជិកគ្រួសាររបស់ខ្ញុំ មានដូចតទៅ:

ក. [redacted]

ខ. [redacted]

គ. [redacted]

ឃ. [redacted]

សូមលោកប្រធានជ្រាប និងទទួលនូវការគោរពពីខ្ញុំបាទ។

ភ្នំពេញ មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ ២០១៩

នួន ជា